ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# **លិខិតជូនពរ**

**សូមគោរពជូន**

**លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា**

**លោកជំទាវកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសនក្ខត្តឫក្សចម្រើនជន្មាយុ របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា** នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវការចូលរួមអបអរសាទរ និងគោរពជូនពរយ៉ាងកក់ក្តៅចំពោះ **លោកជំទាវ** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងមានជន្មាយុយឺនយូរ។

យើងខ្ញុំសូមអនុញ្ញាតសម្តែងនូវទឹកចិត្តយ៉ាងថ្លៃថ្លា និងការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **លោកជំទាវ** ដែលជានិច្ចកាលតែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាល រដ្ឋសភា ក្នុងការបំពេញបេសកកម្មបម្រើផលប្រយោជន៍ **ជាតិ សាសនា ព្រះមហាក្សត្រ** និងបានចូលរួមយ៉ាងសកម្មក្នុងការចូលរួមលើកកម្ពស់តម្លៃ និងតួនាទីរបស់ស្ត្រីកម្ពុជាឱ្យមានការយល់ដឹង និងទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

នាឱកាសដ៏ឧត្តុង្គឧត្តមសិរីមង្គលថ្លៃថ្លានេះ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូន **លោកជំទាវកិត្តិសង្គហបណ្ឌិត** ព្រមទាំង **ក្រុមគ្រួសារ** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃរដ្ឋសភា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃសុក្រ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវេងអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh